ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.០០១.......សហវ.......

ថ្ងៃ ... ខែ ... ឆ្នាំជូត ទោស័ក ព.ស២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២១

**សារាចរណែនាំ**

**ស្តីពី**

**នីតិវិធីនៃការអនុវត្តថវិកា កិច្ចបញ្ជិកាគណនេយ្យ និងចលនាសាច់ប្រាក់នៃការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលក្រុង ស្រុក ទាំង ១៤ នៃខេត្តបាត់ដំបង សម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ**

-យោងប្រកាសអន្តរក្រសួងលេខ ៥២១ សហវ.ប្រក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ ស្តីពីលក្ខខណ្ឌហិរញ្ញវត្ថុ លក្ខខណ្ឌបច្ចេកទេស និងនីតិវិធីហិរញ្ញវត្ថុសម្រាប់ការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលក្រុង ស្រុក ទាំង ១៤ នៃខេត្តបាត់ដំបង សម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ

-យោងប្រកាសលេខ ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា

-យោងប្រកាសលេខ ១២១២ សហវ.ប្រក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ

-យោងប្រកាសលេខ ៧៩០ សហវ.ប្រក ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២០ ស្តីពីការបង្កើតបន្ថែមអនុគណនីនៃមាតិកាថវិកា និងមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ

-យោងប្រកាសលេខ ១២៧២ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ស្តីពីការកែសម្រួលលេខសម្គាល់គណនី ឈ្មោះគណនី ការធ្វើសមាហរណកម្មគណនី និងការបង្កើតបន្ថែមគណនី អនុគណនីនៃមាតិកាថវិកា និងមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ

**ផ្នែកទី ១÷ នីតិវិធីនៃការអនុវត្តថវិកា និងកិច្ចបញ្ជិកាគណនេយ្យ សម្រាប់ការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលក្រុង ស្រុកទាំង ១៤ នៃខេត្តបាត់ដំបង សម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ**

ដើម្បីមានមូលដ្ឋានចុះកិច្ចបញ្ជិកាគណនេយ្យរដ្ឋ គណនេយ្យថវិការដ្ឋបាលក្រុង ស្រុក ការកាន់បញ្ជីចំណូល ចំណាយប្រាក់ដែលបានបើកផ្តល់មុន និងបានទូទាត់ និងការកាន់បញ្ជីបេឡារបស់គ្រឹះស្ថានមត្តេយ្យសិក្សា គ្រឹះស្ថានបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធនៅរដ្ឋបាលក្រុង ស្រុក ទាំង ១៤ នៃខេត្តបាត់ដំបង អង្គភាពពាក់ព័ន្ធត្រូវអនុវត្តដូចខាងក្រោម÷

**I.គោលការណ៍រួមនៃការអនុវត្តចំណូល ចំណាយលើការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ**

**១.** ចំណាយថវិការបស់រដ្ឋបាលថ្នាក់ជាតិក្នុងការផ្តល់ឧបត្ថម្ភធនជូនរដ្ឋបាលក្រុង ស្រុក សម្រាប់អនុវត្តក្នុងក្របខណ្ឌ

ធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌ សម្រាប់វិស័យអប់រំត្រូវកត់ត្រានៅក្នុងអនុគណនី “**ឧបត្ថម្ភធនដល់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌ**” (លេខ ៦៥០១៦)។

២.ចំណូលថវិការបស់រដ្ឋបាលក្រុង ស្រុក ដែលបានពីឧបត្ថម្ភធនពីថ្នាក់ជាតិ សម្រាប់វិស័យអប់រំត្រូវកត់ត្រានៅក្នុងអនុគណនី “**ឧបត្ថម្ភធនពីក្រសួង ស្ថាប័ន សម្រាប់ធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌ**” (លេខ ៧៥០១៦)។

៣.រដ្ឋបាលក្រុង ស្រុក ទាំង ១៤ នៃខេត្តបាត់ដំបង ត្រូវរៀបចំកម្មវិធីចំណាយប្រចាំត្រីមាស ផ្ញើមកមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីបូកសរុប រួចផ្ញើមកអគ្គនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចមានតារាងជូនភ្ជាប់។ រដ្ឋបាលក្រុង ស្រុក ទាំង ១៤ នៃខេត្តបាត់ដំបង ត្រូវចេញអាណត្តិបើកប្រាក់នៅក្នុងវង្វង់នៃកម្មវិធីចំណាយប្រចាំត្រីមាសរបស់ខ្លួន។

៤.នៅដើមឆ្នាំថវិកា ក្នុងករណីដែលគណនីប្រាក់បញ្ញើរបស់រដ្ឋបាលក្រុង ស្រុក ពុំមានសមតុល្យគ្រប់គ្រាន់ សម្រាប់បើកផ្តល់ប្រាក់ចំណាយដំណើរការ យោងតាមកម្មវិធីចំណាយសាច់ប្រាក់ ផ្អែកលើសំណើរបស់គ្រឹះស្ថានមត្តេយ្យសិក្សា គ្រឹះស្ថានបឋមសិក្សា និងមជ្ឈមណ្ឌលសិក្សាសហគមន៍ ឬ មជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ អាណាប័ក (អភិបាលនៃគណៈអភិបាលក្រុង ស្រុក) អាចស្នើសុំផ្តល់បុរេប្រទានបន្ថែមសមតុល្យគណនីប្រាក់បញ្ញើរបស់រដ្ឋបាលក្រុង ស្រុក នៅរតនាគារខេត្ត សម្រាប់ចំណាយដំណើរការរបស់គ្រឹះស្ថានមត្តេយ្យសិក្សា គ្រឹះស្ថានបឋមសិក្សា និងមជ្ឈមណ្ឌលសិក្សាសហគមន៍ ឬ មជ្ឈមណ្ឌលសិក្សាពេញមួយជីវិតនិងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ។ រតនាគារខេត្តជាអ្នកសម្រេចលើការផ្តល់បុរេប្រទានបន្ថែមសមតុល្យគណនីប្រាក់បញ្ញើរបស់រដ្ឋបាលក្រុង ស្រុក នៅរតនាគារខេត្ត។

៥.នៅដើមខែមករានៃឆ្នាំថវិកា រដ្ឋបាលក្រុង ស្រុក ត្រូវរៀបចំអាណត្តិបើកប្រាក់បៀវត្ស ជូនបុគ្គលិកអប់រំរបស់គ្រឹះស្ថានមត្តេយ្យសិក្សា គ្រឹះស្ថានបឋមសិក្សា និងមជ្ឈមណ្ឌលសិក្សាសហគមន៍ ឬ មជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ ដោយឡែកពីប្រាក់បៀវត្សរបស់មន្ត្រី/បុគ្គលិកនៃរដ្ឋបាលក្រុង ស្រុក (ក្រៅពីបុគ្គលិកសិក្សារបស់គ្រឹះស្ថានមត្តេយ្យសិក្សា គ្រឹះស្ថានបឋមសិក្សា និងមជ្ឈមណ្ឌលសិក្សាសហគមន៍ ឬ មជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ)។ ក្នុងករណីសមតុល្យគណនីប្រាក់បញ្ញើរបស់រដ្ឋបាលក្រុង ស្រុក ពុំមានសមតុល្យគ្រប់គ្រាន់ រដ្ឋបាលក្រុង ស្រុក ត្រូវរៀបចំសំណើទៅរតនាគារខេត្តសុំផ្តល់បុរេប្រទានប្រាក់បៀវត្ស ប្រាក់កម្រៃ និងប្រាក់ឧបត្ថម្ភជូនបុគ្គលិកអប់រំរបស់គ្រឹះស្ថានមត្តេយ្យសិក្សា គ្រឹះស្ថានបឋមសិក្សា និងមជ្ឈមណ្ឌលសិក្សាសហគមន៍ ឬ មជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ។ រតនាគារខេត្តជាអ្នកសម្រេចលើការផ្តល់បុរេប្រទានបន្ថែមសមតុល្យគណនីប្រាក់បញ្ញើរបស់រដ្ឋបាលក្រុង ស្រុក នៅរតនាគារខេត្ត។

៦.នៅពេលដែលរដ្ឋបាលក្រុង ស្រុក ទទួលបានឧបត្ថម្ភធន រតនាគារខេត្តត្រូវទូទាត់ជម្រះដោយស្វ័យប្រវត្តិនូវបុរេប្រទានដែលបានផ្តល់សម្រាប់ចំណាយដំណើរការ និងសម្រាប់ចំណាយប្រាក់បៀវត្ស ប្រាក់កម្រៃ ប្រាក់ឧបត្ថម្ភរបស់បុគ្គលិកសិក្សារបស់គ្រឹះស្ថានមត្តេយ្យសិក្សា គ្រឹះស្ថានបឋមសិក្សា និងមជ្ឈមណ្ឌលសិក្សាសហគមន៍ ឬ មជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ រួចជូនដំណឹងទៅរដ្ឋបាលក្រុង ស្រុក។

៧.ការចំណាយថវិកាលើវិស័យអប់រំ និងចំណាយថវិកាផ្ទាល់នៃរដ្ឋបាលក្រុង ស្រុក ត្រូវកត់ត្រានៅក្នុងគណនី ឬ អនុគណនី (មាតិកាគណនីនៃចំណាត់ថ្នាក់សេដ្ឋកិច្ច) ដែលមានចែងនៅក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមាន ប៉ុន្តែត្រូវមានការតាមដានលម្អិតបន្ថែមចំណាយថវិកាសរុបរបស់គ្រឹះស្ថានមត្តេយ្យសិក្សា គ្រឹះស្ថានបឋមសិក្សា និងមជ្ឈមណ្ឌលសិក្សាសហគមន៍ ឬ មជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ ដើម្បីមាន

លក្ខណៈងាយស្រួលអាចដឹងបាននូវការអនុវត្តចំណូល ចំណាយថវិកានេះ ដោយឡែកពីថវិកាផ្ទាល់នៃរដ្ឋបាលក្រុង ស្រុក និងដើម្បីងាយស្រួលក្នុងការប្រមូលសរុបការអនុវត្តថវិការបស់វិស័យអប់រំទាំងមូល។

៨.គណនេយ្យករថវិកាក្រុង ស្រុក ត្រូវកត់ត្រាជារួម នូវប្រតិបត្តិការចំណូល ចំណាយរបស់រដ្ឋបាលក្រុង ស្រុក នៅក្នុងគណនីប្រាក់បញ្ញើរបស់ក្រុង ស្រុក នៅរតនាគារ (លេខ ១២០៣) និងគណនីប្រាក់បញ្ញើរបស់ក្រុង ស្រុក (លេខ ៤៤០៣)។

៩.ចំពោះគណនី ប្រាក់បញ្ញើរបស់ក្រុង ស្រុក នៅរតនាគារខេត្ត (លេខ ១២០៣) គណនីប្រាក់បញ្ញើរបស់ក្រុង ស្រុក (លេខ ៤៤០៣) និងគណនីទានចំណាយថវិកា ត្រូវមានការកត់ត្រាតាមដានបន្ថែមក្នុងប្រព័ន្ធ FMIS សម្រាប់ស្ថានភាពចំណូល ចំណាយប្រាក់នៃថវិការបស់រដ្ឋបាលក្រុង ស្រុកផ្ទាល់ និងថវិកាគ្រឹះស្ថានមត្តេយ្យសិក្សា ឬ គ្រឹះស្ថានបឋមសិក្សា ឬ មជ្ឈមណ្ឌលសិក្សាសហគមន៍ ឬ មជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ។

១០.អាណត្តិបើកប្រាក់ និងអាណត្តិនិយ័តកម្ម និងលិខិតយុត្តិការចំណាយថវិការបស់គ្រឹះស្ថានមត្តេយ្យសិក្សា គ្រឹះស្ថានបឋមសិក្សា និងមជ្ឈមណ្ឌលសិក្សាសហគមន៍ ឬ មជ្ឈមណ្ឌលសិក្សាពេញមួយជីវិតនិងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ នៃរដ្ឋបាលក្រុង ស្រុក ត្រូវបោះផ្សាយដោយឡែកពីអាណត្តិបើកប្រាក់ និងលិខិតយុត្តិការចំណាយថវិកាផ្ទាល់របស់រដ្ឋបាលក្រុង ស្រុក និងត្រូវចុះលេខរៀងបន្តជាមួយអាណត្តិបើកប្រាក់ចំណាយថវិកាផ្ទាល់របស់រដ្ឋបាលក្រុង ស្រុក។ ចំពោះអាណត្តិនិយ័តកម្មត្រូវបោះផ្សាយប្រចាំត្រីមាស។

ការបំពេញនៅលើអាណត្តិបើកប្រាក់÷

-អត្ថគាហកៈ គ្រឹះស្ថានមត្តេយ្យសិក្សា... ឬ គ្រឹះស្ថានបឋមសិក្សា... ឬ មជ្ឈមណ្ឌលសិក្សាសហគមន៍ ឬ មជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ

-កម្មវត្ថុចំណាយ លេខគណនី និងឈ្មោះធនាគារឬរតនាគារ÷

- ចំពោះអាណត្តិនិយ័តកម្មទូទាត់ប្រាក់ដែលបានបើកផ្តល់មុនៈ ចំណាយថវិកាទូទាត់ប្រាក់ដែលបានបើកផ្តល់មុន ថ្ងៃទី...ខែ...ឆ្នាំ២០២១ សម្រាប់ចំណាយដំណើរការនៅ...។ គណនីលេខ ១៥០៥៤។ រតនាគារខេត្តបាត់ដំបង។
- ចំពោះអាណត្តិបើកប្រាក់បៀវត្ស ប្រាក់កម្រៃ និងប្រាក់ឧបត្ថម្ភប្រចាំខែៈ ចំណាយថវិកាទូទាត់ប្រាក់បៀវត្ស ឬ ប្រាក់កម្រៃ...ប្រចាំខែ... ឆ្នាំ...។ គណនីលេខ ៤២០១...។ រតនាគារខេត្តបាត់ដំបង។
- ចំពោះអាណត្តិនិយ័តកម្មទូទាត់ជម្រះបុរេប្រទានប្រាក់បៀវត្ស ប្រាក់កម្រៃ និងប្រាក់ឧបត្ថម្ភប្រចាំខែៈ ចំណាយថវិកាទូទាត់ជម្រះបុរេប្រទានប្រាក់បៀវត្ស ប្រាក់កម្រៃ និងប្រាក់ឧបត្ថម្ភប្រចាំខែ... ឆ្នាំ...។ លេខគណនី ១៥០៥៦។ រតនាគារខេត្តបាត់ដំបង។
- ក្នុងករណីអាណត្តិបើកប្រាក់ចំណាយបៀវត្ស ប្រាក់កម្រៃ និងប្រាក់ឧបត្ថម្ភ បានបោះផ្សាយរួច ដោយមានកម្មវត្ថុជាចំណាយថវិកា លើប្រាក់បៀវត្ស ប្រាក់កម្រៃ និងប្រាក់ឧបត្ថម្ភ ប្រចាំខែ...ឆ្នាំ... ហើយកំពុងដំណើរការ និងពុំទាន់មកដល់រតនាគារខេត្ត ក៏ប៉ុន្តែ រដ្ឋបាលក្រុង ស្រុកបានទទួលបុរេប្រទានប្រាក់បៀវត្ស ប្រាក់កម្រៃ និងប្រាក់ឧបត្ថម្ភពីរតនាគារខេត្តរួចហើយ រតនាគារខេត្តត្រូវកែតម្រូវលើកម្មវត្ថុនៃការចំណាយលើអាណត្តិបើកប្រាក់នោះទៅជាៈ ចំណាយថវិកាទូទាត់ជម្រះបុរេប្រទានប្រាក់បៀវត្ស ឬ ប្រាក់កម្រៃ ឬ ប្រាក់ឧបត្ថម្ភ ប្រចាំខែ...។ លេខគណនី ១៥០៥៦។ រតនាគារខេត្តបាត់ដំបង។

១១.គណនេយ្យករថវិកាក្រុង ស្រុក ត្រូវចុះកិច្ចបញ្ជិកា និងតាមដានជារួម ក្នុងគណនីចំណាយមុនការធ្វើអាណត្តិកិច្ច (លេខ ១៥០៥៨) នូវចំនួនទឹកប្រាក់ដែលបានបើកផ្តល់ជូនគ្រឹះស្ថានមត្តេយ្យសិក្សា ឬ គ្រឹះស្ថានបឋមសិក្សា ឬ មជ្ឈមណ្ឌលសិក្សាសហគមន៍ ឬ មជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ។

១២.ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ត្រូវកត់ត្រាតាមដានជារួម នូវចំនួនទឹកប្រាក់ចំណូលដែលគ្រឹះស្ថានមត្តេយ្យសិក្សា គ្រឹះស្ថានបឋមសិក្សា និងមជ្ឈមណ្ឌលសិក្សាសហគមន៍ ឬ មជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ បានទទួលពីរតនាគារខេត្ត និងចំនួនទឹកប្រាក់ដែលគ្រឹះស្ថាន និងមជ្ឈមណ្ឌលទាំងនោះបានចំណាយ (ទូទាត់) ដោយមានរបាយការណ៍ ព្រមទាំងមានការតាមដានលម្អិតនូវចំនួនទឹកប្រាក់ចំណូល ចំណាយ សម្រាប់គ្រឹះស្ថាន និងមជ្ឈមណ្ឌលនីមួយៗដោយឡែកពីគ្នា។

## II.ការអនុវត្តចំណូល ចំណាយលើការអប់រំកុមារតូច និងការអប់រំបឋមសិក្សានៃរដ្ឋបាលក្រុង ស្រុក

### ១.គោលការណ៍នៃការអនុវត្តចំណូល ចំណាយ

១.១.រដ្ឋបាលក្រុង ស្រុក ត្រូវស្នើសុំទៅរតនាគារខេត្ត តាមរយៈមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត ដើម្បីផ្តល់ប្រាក់មុនសម្រាប់ដំណើរការសាលារៀនជូនគ្រឹះស្ថានមត្តេយ្យសិក្សា និងគ្រឹះស្ថានអប់រំបឋមសិក្សា ដែលត្រូវបើកផ្តល់ជា ០២លើកក្នុងមួយឆ្នាំ គឺលើកទី១ នៅដើមខែមករា និងលើកទី២ នៅដើមខែមិថុនា នៃឆ្នាំនីមួយៗ តាមកម្មវិធីចំណាយសាច់ប្រាក់។ ការបោះផ្សាយអាណត្តិនិយ័តកម្មទូទាត់ចំណាយសម្រាប់ដំណើរការសាលារៀន ដែលបានបើកផ្តល់ប្រាក់មុន គឺធ្វើឡើងប្រចាំត្រីមាសនីមួយៗ។

១.២.រដ្ឋបាលក្រុង ស្រុក ត្រូវបោះផ្សាយអាណត្តិបើកប្រាក់បញ្ជូនទៅរតនាគារខេត្ត តាមរយៈមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត ដើម្បីបើកប្រាក់បៀវត្សនៅរៀងរាល់ ២សប្តាហ៍ម្តង ក្នុងខែនីមួយៗ ជូនបុគ្គលិកអប់រំនៅតាមគ្រឹះស្ថានមត្តេយ្យសិក្សា និងគ្រឹះស្ថានបឋមសិក្សា ដោយផ្អែកតាមតារាងបៀវត្សរបស់ក្រសួងមុខងារសាធារណៈ និងកម្មវិធីចំណាយប្រចាំត្រីមាស។

១.៣.គ្រឹះស្ថានមត្តេយ្យសិក្សា និងគ្រឹះស្ថានអប់រំបឋមសិក្សា ត្រូវកាន់បញ្ជីតាមដានប្រាក់នៅធនាគារ និង/ឬ បញ្ជីបេឡានូវទឹកប្រាក់ដែលបានទទួល និងបានចំណាយ។

-ការកត់ត្រាចំនួនទឹកប្រាក់ក្នុងបញ្ជីតាមដានប្រាក់នៅធនាគារ ដោយយោងតាមប្រកាសឥណពន្ធ ឬ បណ្ណដកប្រាក់ ឬ ប្រកាសឥណទាន ឬ បណ្ណបង់ប្រាក់ ឬ របាយការណ៍របស់ធនាគារ (Bank Statement)។ បញ្ជីតាមដានប្រាក់នៅធនាគារត្រូវផ្ទៀងផ្ទាត់ជាមួយរបាយការណ៍របស់ធនាគារ។

-ការកត់ត្រាចំនួនទឹកប្រាក់ក្នុងបញ្ជីបេឡា ដោយយោងតាមបណ្ណចំណូល ឬ បណ្ណចំណាយ។ ចំនួនទឹកប្រាក់សល់ក្នុងបញ្ជីបេឡាត្រូវផ្ទៀងផ្ទាត់ជាមួយចំនួនសាច់ប្រាក់ជាក់ស្តែង។

### ១.៤.ការបង់ប្រាក់សល់ពីការចំណាយ

ទឹកប្រាក់បានបើកផ្តល់មុន ដែលសល់ពីចំណាយត្រូវបង់ចូលរតនាគារខេត្តវិញ។ គណនេយ្យករថវិកាក្រុង ស្រុក ត្រូវផ្ទេរតួលេខលម្អៀងរវាងចំណូលថវិកាបានពីឧបត្ថម្ភធនពីក្រសួង ស្ថាប័ន សម្រាប់ធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌ (លេខ ៧៥០១៦) និងតួលេខចំណាយសរុបរបស់គ្រឹះស្ថានមត្តេយ្យសិក្សា និងគ្រឹះស្ថានអប់រំបឋមសិក្សាមករតនាគារថ្នាក់កណ្តាល ដើម្បីកត់ត្រាជាសំណៃសចំណាយ។

### ២.កិច្ចបញ្ជិកាគណនេយ្យ

### ២.១.ការផ្តល់បុរេប្រទានដល់រដ្ឋបាលក្រុង ស្រុក

នៅដើមឆ្នាំថវិកា ក្នុងករណីគណនីប្រាក់បញ្ញើរបស់ក្រុង ស្រុក ពុំមានសមតុល្យគ្រប់គ្រាន់សម្រាប់បើកផ្តល់ប្រាក់

សម្រាប់ចំណាយដំណើរការ យោងសំណើរបស់រដ្ឋបាលក្រុង ស្រុក រតនាគារខេត្តកត់ត្រាការផ្ដល់បុរេប្រទានដោយបំពេញសមតុល្យគណនីប្រាក់បញ្ញើរបស់រដ្ឋបាលក្រុង ស្រុក នៅរតនាគារខេត្ត។

ការកត់ត្រា÷

**-កិច្ចបញ្ជិការបស់រតនាគារខេត្ត (គណនេយ្យថវិកាក្រុង ស្រុក)**

ឥណពន្ធ គណនី ប្រាក់បញ្ញើរបស់ក្រុង ស្រុក ខណ្ឌ នៅរតនាគារ (លេខ ១២០៣)

ឥណទាន គណនី បុរេប្រទានឬរដ្ឋទេយ្យបុរេប្រទានបានទទួល (លេខ ៤០០៥)។

**-កិច្ចបញ្ជិការបស់រតនាគារខេត្ត (គណនេយ្យថវិកាថ្នាក់ជាតិ)**

ឥណពន្ធ គណនី បុរេប្រទានបន្ថែមសមតុល្យគណនីប្រាក់បញ្ញើ (លេខ ១៥០៥៧)

ឥណទាន គណនី ប្រាក់បញ្ញើថវិការបស់ក្រុង ស្រុក ខណ្ឌ (លេខ ៤៤០៣)។

**២.២.ការបើកផ្ដល់ប្រាក់សម្រាប់ចំណាយដំណើរការ ជូនគ្រឹះស្ថានមត្តេយ្យសិក្សា និងគ្រឹះស្ថានបឋមសិក្សា តាមរយៈការបោះផ្សាយមូលប្បទានបត្រ**

**២.២.១. ពេលរតនាគារខេត្ត (គណនេយ្យថវិកាថ្នាក់ជាតិ) បោះផ្សាយមូលប្បទានបត្រ**

**-កិច្ចបញ្ជិការបស់រតនាគារខេត្ត (គណនេយ្យថវិកាក្រុង ស្រុក)**

គណនេយ្យករដែលកាន់គណនេយ្យថវិកាក្រុង ស្រុក ត្រូវប្រគល់សលាកបត្រចុះលេខនា និងសំណើសុំរតនាគារខេត្តបើកផ្ដល់ប្រាក់មុន ទៅគណនេយ្យករថវិកាថ្នាក់ជាតិ ដើម្បីបោះផ្សាយមូលប្បទានបត្រ។

ការកត់ត្រា÷

ឥណពន្ធ គណនី ចំណាយមុនការធ្វើអាណត្តិកិច្ច (លេខ ១៥០៥៤)

ឥណទាន គណនី ប្រាក់បញ្ញើថវិការបស់ក្រុង ស្រុក ខណ្ឌ នៅរតនាគារ (លេខ ១២០៣)។

**-កិច្ចបញ្ជិការបស់រតនាគារខេត្ត (គណនេយ្យថវិកាថ្នាក់ជាតិ)**

**ក្រោយពីគណនេយ្យករថវិកាថ្នាក់ជាតិ បានបោះផ្សាយមូលប្បទានបត្រ**

**ការកត់ត្រា÷**

ឥណពន្ធ គណនី ប្រាក់បញ្ញើថវិការបស់ក្រុង ស្រុក ខណ្ឌ (លេខ ៤៤០៣)

ឥណទាន គណនី មូលប្បទានបត្រ ឬ បញ្ជាផ្ទេរបានបោះផ្សាយ (លេខ ១១០៧) ។

**២.២.២.ពេលធនាគារទូទាត់មូលប្បទានបត្ររបស់រតនាគារ**

ការកត់ត្រា÷

**-កិច្ចបញ្ជិការបស់រតនាគារខេត្ត (គណនេយ្យថវិកាថ្នាក់ជាតិ)**

ឥណពន្ធ គណនី មូលប្បទានបត្រឬបញ្ជាផ្ទេរបានបោះផ្សាយ (លេខ ១១០៧)

ឥណទាន គណនី ចរន្តនៅធនាគារ (លេខ ១១២១../១១៣១..)។

**២.៣.ការបើកផ្ដល់ប្រាក់សម្រាប់ចំណាយដំណើរការ ដោយផ្ទេរប្រាក់ពីគណនីចរន្តរបស់រតនាគារខេត្តនៅធនាគារទៅគណនីរបស់គ្រឹះស្ថានមត្តេយ្យសិក្សា និងគ្រឹះស្ថានបឋមសិក្សានៅធនាគារ ការកត់ត្រា÷**

-កិច្ចបញ្ជិការបស់រតនាគារខេត្ត (គណនេយ្យថវិកាក្រុង ស្រុក)

ឥណពន្ធ គណនី ចំណាយមុនការធ្វើអាណត្តិកិច្ច (លេខ ១៥០៥៤)

ឥណទាន គណនី ប្រាក់បញ្ញើថវិការបស់ក្រុង ស្រុក ខណ្ឌ នៅរតនាគារ (លេខ ១២០៣)។

-កិច្ចបញ្ជីការបស់រតនាគារខេត្ត (គណនេយ្យថវិកាថ្នាក់ជាតិ)

ឥណពន្ធ គណនី ប្រាក់បញ្ញើថវិការបស់ក្រុង ស្រុក ខណ្ឌ (លេខ ៤៤០៣)

ឥណទាន គណនី ចរន្តនៅធនាគារ (លេខ ១១២១/១១៣១)។

**បញ្ជាក់:** -គណនេយ្យករដែលកាន់គណនេយ្យថវិកាក្រុង ស្រុក ត្រូវពិនិត្យ បញ្ជូនសលាកបត្រចុះលេខនា និងសំណើរបស់រដ្ឋបាលក្រុង ស្រុក សុំដកប្រាក់ ទៅគណនេយ្យករថវិកាថ្នាក់ជាតិ

-គណនេយ្យករថវិកាក្រុង ស្រុក ត្រូវផ្តល់សក្ខីបត្រទាក់ទងនឹងការផ្ទេរប្រាក់ជូនគ្រឹះស្ថានមត្តេយ្យសិក្សា និងគ្រឹះស្ថានបឋមសិក្សានីមួយៗ ទៅរដ្ឋបាលក្រុង ស្រុក។

-រដ្ឋបាលក្រុង ស្រុក ត្រូវផ្តល់ឯកសារអំពីការផ្ទេរប្រាក់ជូនគ្រឹះស្ថានមត្តេយ្យសិក្សា និងគ្រឹះស្ថានបឋមសិក្សានីមួយៗ ទៅការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ដើម្បីកត់ត្រាក្នុងបញ្ជីតាមដានជារួមនូវចំនួនទឹកប្រាក់ចំណូល ចំណាយ ដែលបានបើកផ្តល់មុនជារួម និងកត់ត្រាតាមដានលម្អិត ក្នុងបញ្ជីតាមដានសម្រាប់គ្រឹះស្ថាន មត្តេយ្យសិក្សានិងគ្រឹះស្ថានបឋមសិក្សានីមួយៗ។

**២.៤.ការកាន់បញ្ជីរបស់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក**

-ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ត្រូវកាន់បញ្ជីតាមដានចំណូល ចំណាយប្រាក់ដែលគ្រឹះស្ថានមត្តេយ្យសិក្សា និងគ្រឹះស្ថានបឋមសិក្សានីមួយៗបានទទួល និងបានទូទាត់។

-ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ត្រូវកត់ត្រានៅក្ខឡោនប្រាក់ចំណូលក្នុងបញ្ជីតាមដានចំណូល ចំណាយប្រាក់ដែលបានបើកផ្តល់មុន នៅពេលគ្រឹះស្ថានមត្តេយ្យសិក្សា និងគ្រឹះស្ថានបឋមសិក្សា បានទទួលប្រាក់ពីរតនាគារខេត្ត។

-ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ត្រូវកត់ត្រានៅក្នុងក្ខឡោនប្រាក់ចំណាយនៃបញ្ជីតាមដានចំណូល ចំណាយប្រាក់ដែលបានបើកផ្តល់មុន នៅពេលដែលគ្រឹះស្ថានមត្តេយ្យសិក្សានិងគ្រឹះស្ថានបឋមសិក្សាបានទូទាត់ចំណាយ (យោងរបាយការណ៍ចំណាយ) ឬ បង្វិលសាច់ប្រាក់ដែលនៅសល់ពីចំណាយចូលគណនីធនាគាររបស់រតនាគារខេត្តវិញ។

-ចំនួនទឹកប្រាក់នៅសល់ក្នុងបញ្ជីតាមដានចំណូល ចំណាយប្រាក់ដែលបានបើកផ្តល់មុន គឺបង្ហាញចំនួនទឹកប្រាក់ដែលគ្រឹះស្ថានមត្តេយ្យសិក្សា និងគ្រឹះស្ថានបឋមសិក្សាពុំទាន់បានចំណាយ។ (គំរូបញ្ជីតាមដានចំណូល ចំណាយប្រាក់ដែលបានបើកផ្តល់មុនមានភ្ជាប់ជាមួយសារាចរណែនាំនេះ)។

**២.៥.ការកាន់បញ្ជីបេឡារបស់គ្រឹះស្ថានមត្តេយ្យសិក្សា និងគ្រឹះស្ថានបឋមសិក្សា**

-គ្រឹះស្ថានមត្តេយ្យសិក្សា និងគ្រឹះស្ថានបឋមសិក្សា ត្រូវចាត់ចែងឱ្យហេរញ្ញិកកាន់បញ្ជីចំនួន០២គឺបញ្ជីតាមដានប្រាក់នៅធនាគារ និងបញ្ជីបេឡា។ (បញ្ជីតាមដានប្រាក់នៅធនាគារ និងបញ្ជីបេឡាមានគំរូភ្ជាប់ជាមួយសារាចរណែនាំនេះ)។

-នៅដំណាច់ខែនីមួយៗ ហេរញ្ញិកនៃគ្រឹះស្ថានមត្តេយ្យសិក្សា និងគ្រឹះស្ថានបឋមសិក្សាត្រូវបូកសរុបតួលេខចំណូលចំណាយនៃបញ្ជីតាមដានប្រាក់នៅធនាគារ រួចផ្ទៀងផ្ទាត់ជាមួយរបាយការណ៍របស់ធនាគារ និងត្រូវផ្ទៀងផ្ទាត់ចំនួនទឹកប្រាក់ក្នុងបញ្ជីបេឡា ជាមួយចំនួនសាច់ប្រាក់នៅសល់ជាក់ស្តែង។

**២.៦.** នៅពេលទទួលបានប្រកាសឥណទាន ឬ របាយការណ៍របស់ធនាគារ ស្តីពីការផ្ទេរប្រាក់ចូលក្នុងគណនីរបស់គ្រឹះស្ថានមត្តេយ្យសិក្សា និងគ្រឹះស្ថានបឋមសិក្សា ហេរញ្ញិកត្រូវកត់ត្រានៅក្នុងក្ខឡោនប្រាក់ចំណូលនៃបញ្ជីតាមដានប្រាក់នៅធនាគារ។

**២.៧.** គ្រឹះស្ថានមត្តេយ្យសិក្សា និងគ្រឹះស្ថានបឋមសិក្សា អាចចំណាយប្រាក់ដោយផ្ទាល់ពីគណនីនៅធនាគារ ដូចជា ការទិញសម្ភារ ឬ សេវាកម្ម...។ យោងតាមប្រកាសឥណពន្ធ ឬ បណ្ណដកប្រាក់ ឬ របាយការណ៍របស់ធនាគារ ហេរញ្ញិកត្រូវកត់ត្រាក្នុងក្ងឡោនចំណាយនៃបញ្ជីតាមដានប្រាក់នៅធនាគារ។

**២.៨.** គ្រឹះស្ថានមត្តេយ្យសិក្សា និងគ្រឹះស្ថានបឋមសិក្សា អាចរៀបចំសំណើ ឬ ចេញមូលប្បទានបត្រដកប្រាក់ពីគណនីនៅធនាគារបញ្ចូលក្នុងបេឡា។ យោងតាមប្រកាសឥណពន្ធ ឬ បណ្ណដកប្រាក់ ឬ របាយការណ៍របស់ធនាគារ ហេរញ្ញិកត្រូវកត់ត្រាក្នុងក្ងឡោនចំណាយនៃបញ្ជីតាមដានប្រាក់នៅធនាគារ។ ទន្ទឹមនោះ យោងតាមប្រកាសឥណពន្ធ ឬ បណ្ណដកប្រាក់ ឬ របាយការណ៍របស់ធនាគារ ហេរញ្ញិករៀបចំបណ្ណចំណូល រួចកត់ត្រាក្នុងក្ងឡោនចំណូលនៃបញ្ជីបេឡា។

**២.៩.** នៅពេលគ្រឹះស្ថានមត្តេយ្យសិក្សា និងគ្រឹះស្ថានបឋមសិក្សាបានចំណាយប្រាក់ពីបេឡាទិញសម្ភារ ឬ សេវា... ហេរញ្ញិកត្រូវកត់ត្រាក្នុងក្ងឡោនចំណាយនៃបញ្ជីបេឡា ដោយយោងតាមបណ្ណចំណាយ។

**២.១០. ការរៀបចំរបាយការណ៍ចំណាយថវិកា**

គ្រឹះស្ថានមត្តេយ្យសិក្សា និងគ្រឹះស្ថានបឋមសិក្សាត្រូវរៀបចំរបាយការណ៍ចំណាយ (មានគំរូ) ប្រចាំខែ ជូនការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ដើម្បីបូកសរុប និងស្នើទៅការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុនៃរដ្ឋបាលក្រុង ស្រុក ដើម្បីបោះផ្សាយអាណត្តិនិយ័តកម្ម ទូទាត់ប្រាក់ដែលគ្រឹះស្ថានបានទទួលនៅគ្រាមុន។ អាណត្តិនិយ័តកម្មត្រូវបោះផ្សាយប្រចាំត្រីមាស។

**២.១១.** ក្រោយពីទទួលបានរបាយការណ៍ចំណាយពីគ្រឹះស្ថានមត្តេយ្យសិក្សា និងគ្រឹះស្ថានបឋមសិក្សា ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ត្រូវកត់ត្រាក្នុងបញ្ជីតាមដានជារួម នូវចំនួនទឹកប្រាក់ចំណូល ចំណាយ ដែលបានបើកផ្តល់មុន និងត្រូវកត់ត្រា តាមដានលម្អិតទៅក្នុងបញ្ជីតាមដានសម្រាប់គ្រឹះស្ថាននីមួយៗ។

**III. ការអនុវត្តចំណូល ចំណាយ លើការអប់រំក្រៅប្រព័ន្ធនៃរដ្ឋបាលក្រុង ស្រុក**

**១. គោលការណ៍នៃការអនុវត្តចំណូល ចំណាយ**

**១.១. ការផ្តល់បុរេប្រទានដល់រដ្ឋបាលក្រុង ស្រុក**

នៅដើមឆ្នាំថវិកា ក្នុងករណីគណនីប្រាក់បញ្ញើរបស់ក្រុង ស្រុក ពុំមានសមតុល្យគ្រប់គ្រាន់សម្រាប់បើកផ្តល់ប្រាក់យោងសំណើរបស់រដ្ឋបាលក្រុង ស្រុក រតនាគារខេត្តកត់ត្រាការផ្តល់បុរេប្រទាន ដោយបំពេញសមតុល្យគណនីប្រាក់បញ្ញើរបស់រដ្ឋបាលក្រុង ស្រុក នៅរតនាគារខេត្ត។ រតនាគារខេត្ត ជាអ្នកសម្រេចលើការផ្តល់បុរេប្រទានដល់រដ្ឋបាលក្រុង ស្រុក។

**១.២.** រដ្ឋបាលក្រុង ស្រុក ត្រូវស្នើសុំទៅរតនាគារខេត្ត តាមរយៈមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីផ្តល់ប្រាក់មុនសម្រាប់ចំណាយលើដំណើរការរបស់មជ្ឈមណ្ឌលសិក្សាសហគមន៍ ឬ មជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ ដោយត្រូវបើកផ្តល់ជា ០២លើក ក្នុង ១ឆ្នាំ គឺលើកទី ១ នៅដើមខែមករា និងលើកទី ២ នៅដើមខែមិថុនា។ ការបោះផ្សាយអាណត្តិនិយ័តកម្មទូទាត់ចំណាយសម្រាប់ដំណើរការដែលបានបើកផ្តល់ប្រាក់មុនគឺធ្វើឡើងប្រចាំត្រីមាសនីមួយៗ។

**១.៣.** ទឹកប្រាក់ដែលរតនាគារបានផ្តល់មុន សម្រាប់ចំណាយដំណើរការរបស់មជ្ឈមណ្ឌលសិក្សាសហគមន៍ ឬ មជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ ត្រូវបញ្ចូលទៅក្នុងគណនីរបស់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក។

**១.៤.** រដ្ឋបាលក្រុង ស្រុក ត្រូវបោះផ្សាយអាណត្តិបើកប្រាក់ទៅរតនាគារខេត្ត តាមរយៈមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីបើកប្រាក់ឧបត្ថម្ភប្រចាំខែ ជូនគ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធ នៅតាមមជ្ឈមណ្ឌលសិក្សាសហគមន៍ ឬ

មជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ ផ្អែកតាមកិច្ចសន្យាបំពេញការងារ និងរបបប្រាក់ឧបត្ថម្ភប្រចាំខែ ដែលបានកំណត់ និងផ្អែកតាមកម្មវិធីចំណាយប្រចាំត្រីមាស។

១.៥.ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ត្រូវកាន់បញ្ជីតាមដានប្រាក់នៅធនាគារ នូវទឹកប្រាក់ដែលបានទទួលពីរតនាគារ និងបានចំណាយដោយកត់ត្រាក្នុងបញ្ជីតាមដានប្រាក់នៅធនាគារ យោងតាមប្រកាសឥណពន្ធ ឬ បណ្ណដកប្រាក់ ឬ ប្រកាសឥណទាន ឬ បណ្ណបង់ប្រាក់ ឬ របាយការណ៍របស់ធនាគារ។ បញ្ជីតាមដានប្រាក់នៅធនាគារត្រូវផ្ទៀងផ្ទាត់ជាមួយរបាយការណ៍របស់ធនាគារ។

**២.កិច្ចបញ្ជិកាគណនេយ្យ**

**២.១.ការផ្តល់បុរេប្រទានដល់រដ្ឋបាលក្រុង ស្រុក**

រតនាគារខេត្ត កត់ត្រាបុរេប្រទានបន្ថែមសមតុល្យគណនីប្រាក់បញ្ញើរបស់រដ្ឋបាលក្រុង ស្រុក នៅរតនាគារខេត្ត។

ការកត់ត្រា÷

**-កិច្ចបញ្ជិការបស់រតនាគារខេត្ត (គណនេយ្យថវិកាក្រុង ស្រុក)**

ឥណពន្ធ គណនី ប្រាក់បញ្ញើរបស់ក្រុង ស្រុក ខណ្ឌ នៅរតនាគារ (លេខ ១២០៣)

ឥណទាន គណនី បុរេប្រទាន ឬ រដ្ឋទេយ្យបុរេប្រទានបានទទួល (លេខ ៤០០៥)។

**-កិច្ចបញ្ជិការបស់រតនាគារខេត្ត (គណនេយ្យថវិកាថ្នាក់ជាតិ)**

ឥណពន្ធ គណនី បុរេប្រទានបន្ថែមសមតុល្យគណនីប្រាក់បញ្ញើ (លេខ ១៥០៥៧)

ឥណទាន គណនី ប្រាក់បញ្ញើថវិការបស់ក្រុង ស្រុក ខណ្ឌ (លេខ ៤៤០៣)។

**២.២.ការបើកផ្តល់ប្រាក់ជូនការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក តាមការបោះផ្សាយមូលប្បទានបត្រ**

**២.២.១. ពេលរតនាគារខេត្តប្រគល់មូលប្បទានបត្រ**

**-កិច្ចបញ្ជិការបស់រតនាគារខេត្ត (គណនេយ្យថវិកាក្រុង ស្រុក)**

គណនេយ្យករដែលកាន់គណនេយ្យថវិកាក្រុង ស្រុក ត្រូវប្រគល់សលាកបត្រចុះលេខនា និងសំណើសុំរតនាគារខេត្តផ្តល់ប្រាក់មុនជូនរបស់រដ្ឋបាលក្រុង ស្រុក ទៅគណនេយ្យករថវិកាក្រុង ស្រុក។

ការកត់ត្រា÷

ឥណពន្ធ គណនី ចំណាយមុនការធ្វើអាណត្តិកិច្ច (លេខ ១៥០៥៤)

ឥណទាន គណនី ប្រាក់បញ្ញើថវិការបស់ក្រុង ស្រុក ខណ្ឌ នៅរតនាគារ (លេខ ១២០៣)។

**-កិច្ចបញ្ជិការបស់រតនាគារខេត្ត (គណនេយ្យថវិកាថ្នាក់ជាតិ)**

ឥណពន្ធ គណនី ប្រាក់បញ្ញើថវិការបស់ក្រុង ស្រុក ខណ្ឌ (លេខ ៤៤០៣)

ឥណទាន គណនី មូលប្បទានបត្រ ឬ បញ្ជាផ្ទេរបានបោះផ្សាយ (លេខ ១១០៧)។

**២.២.២.ពេលធនាគារទូទាត់មូលប្បទានបត្ររបស់រតនាគារ**

ការកត់ត្រា÷

**-កិច្ចបញ្ជិការបស់រតនាគារខេត្ត (គណនេយ្យថវិកាថ្នាក់ជាតិ)**

ឥណពន្ធ គណនី មូលប្បទានបត្រ ឬ បញ្ជាផ្ទេរបានបោះផ្សាយ (លេខ ១១០៧)

ឥណទាន គណនី ចរន្តនៅធនាគារ (លេខ ១១២១.../១១៣១...)។

**២.៣.ការបើកផ្តល់ប្រាក់ សម្រាប់ចំណាយដំណើរការដោយផ្ទេរពីគណនីចរន្តរបស់រតនាគារទៅគណនីរបស់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុកនៅធនាគារ**

**-កិច្ចបញ្ជិការរបស់រតនាគារខេត្ត (គណនេយ្យថវិកាក្រុង ស្រុក)**

ឥណពន្ធ គណនី ចំណាយមុនការធ្វើអាណត្តិកិច្ច (លេខ ១៥០៥៤)

ឥណទាន គណនី ប្រាក់បញ្ញើថវិការបស់ក្រុង ស្រុក ខណ្ឌ នៅរតនាគារ (លេខ ១២០៣)។

**-កិច្ចបញ្ជិការរបស់រតនាគារខេត្ត (គណនេយ្យថវិកាថ្នាក់ជាតិ)**

ឥណពន្ធ គណនី ប្រាក់បញ្ញើថវិការបស់ក្រុង ស្រុក ខណ្ឌ (លេខ ៤៤០៣)

ឥណទាន គណនី ចរន្តនៅធនាគារ (លេខ ១១២១.../១១៣១...) ។

បញ្ជាក់ៈ
- គណនេយ្យករដែលកាន់គណនេយ្យថវិកាក្រុង ស្រុក ត្រូវប្រគល់សលាបត្រចុះលេខនា និងសំណើរបស់រដ្ឋបាលក្រុង ស្រុក សុំផ្តល់ប្រាក់មុនសម្រាប់ចំណាយដំណើរការរបស់មជ្ឈមណ្ឌលសិក្សាសហគមន៍ ឬ មជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ ទៅគណនេយ្យករថវិកាថ្នាក់ជាតិ។
- គណនេយ្យករថវិកាក្រុង ស្រុក ត្រូវជូនដំណឹងទៅរដ្ឋបាលក្រុង ស្រុក អំពីពេលវេលា និងចំនួនទឹកប្រាក់ដែលរតនាគារខេត្តបានផ្ទេរត្រង់ចូលគណនីរបស់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក។
- រដ្ឋបាលក្រុង ស្រុក ត្រូវផ្តល់ឯកសារអំពីការផ្ទេរប្រាក់ជូនការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ដើម្បីកត់ត្រាក្នុងក្ងឡោនចំណូលប្រាក់នៃបញ្ជីតាមដានប្រាក់នៅធនាគារ។

**២.៤.ការកាន់បញ្ជីបេឡារបស់មជ្ឈមណ្ឌលសិក្សាសហគមន៍ ឬ មជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ**

-មជ្ឈមណ្ឌលសិក្សាសហគមន៍ ឬ មជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ ត្រូវចាត់ចែងឱ្យហេរញ្ញិកកាន់បញ្ជីបេឡា (បញ្ជីបេឡាមានគំរូភ្ជាប់ជាមួយសារាចរណែនាំនេះ)។

-នៅដំណាច់ខែនីមួយៗ ហេរញ្ញិកនៃមជ្ឈមណ្ឌលសិក្សាសហគមន៍ ឬ មជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ ត្រូវបូកសរុបតួលេខចំណូល ចំណាយ និងត្រូវផ្ទៀងផ្ទាត់ចំនួនទឹកប្រាក់នៅសល់ក្នុងបញ្ជីបេឡាជាមួយចំនួនសាច់ប្រាក់នៅសល់ជាក់ស្តែង។

**២.៥.**នៅពេលមជ្ឈមណ្ឌលសិក្សាសហគមន៍ ឬ មជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ បានចំណាយប្រាក់ពីបេឡាទិញសម្ភារ សេវា... យោងតាមបណ្ណចំណាយ ហេរញ្ញិកត្រូវកត់ត្រាក្នុងក្ងឡោនចំណាយប្រាក់នៃបញ្ជីបេឡា។

**២.៦.ការរៀបចំរបាយការណ៍ចំណាយថវិកា**

មជ្ឈមណ្ឌលសិក្សាសហគមន៍ ឬ មជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ ត្រូវរៀបចំរបាយការណ៍ចំណូល ចំណាយ (មានគំរូ) ប្រចាំខែ ដើម្បីទូទាត់ចំណាយប្រាក់ដែលបានទទួល និងបានទូទាត់ជូនការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ដើម្បីបូកសរុប និងស្នើទៅការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុនៃរដ្ឋបាលក្រុង ស្រុក ដើម្បីបោះផ្សាយអាណត្តិនិយ័តកម្ម ទូទាត់ជាមួយប្រាក់ដែលមជ្ឈមណ្ឌលសិក្សាសហគមន៍ ឬ មជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ បានទទួលពីរតនាគារ។ អាណត្តិនិយ័តកម្មត្រូវបោះផ្សាយប្រចាំត្រីមាស។

២.៧.ក្រោយពីទទួលបានអាណត្តិនិយ័តកម្មទូទាត់ប្រាក់ដែលបានបើកផ្តល់មុន គណនេយ្យថវិកាក្រុង ស្រុកកត់ត្រា÷

ឥណពន្ធ គណនី ចំណាយថវិកា (លេខ ៦...)

ឥណទាន គណនី ចំណាយមុនការធ្វើអាណត្តិកិច្ច (លេខ ១៥០៥៤)។

**IV.កិច្ចបញ្ជិកាគណនេយ្យបើកផ្តល់បៀវត្ស ប្រាក់កម្រៃ ប្រាក់ឧបត្ថម្ភដល់គ្រឹះស្ថានមត្តេយ្យសិក្សា គ្រឹះស្ថានបឋមសិក្សា និងមជ្ឈមណ្ឌលសិក្សាសហគមន៍ ឬ មជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ**

-ក្នុងករណីមានឥណទានគ្រប់គ្រាន់ រដ្ឋបាលក្រុង ស្រុក ត្រូវរួតរះបោះផ្សាយអាណត្តិបើកប្រាក់បៀវត្ស ប្រាក់កម្រៃ ប្រាក់ឧបត្ថម្ភដល់គ្រឹះស្ថានមត្តេយ្យសិក្សា គ្រឹះស្ថានបឋមសិក្សា និងមជ្ឈមណ្ឌលសិក្សាសហគមន៍ ឬ មជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ ប្រចាំខែ ឱ្យបានទាន់ពេលវេលា។

-ក្នុងករណីពុំមានឥណទានគ្រប់គ្រាន់ រដ្ឋបាលក្រុង ស្រុក ត្រូវរៀបចំសំណើសុំផ្តល់បុរេប្រទានបៀវត្ស ប្រាក់កម្រៃ ប្រាក់ឧបត្ថម្ភ ប្រចាំខែ មករតនាគារខេត្ត ស្នើសុំការសម្រេចផ្តល់បុរេប្រទាន និងត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម÷

**១.ពេលផ្តល់បុរេប្រទាន**

ការកត់ត្រា÷

**-កិច្ចបញ្ជិការបស់រតនាគារខេត្ត (គណនេយ្យថវិកាក្រុង ស្រុក)**

ឥណពន្ធ គណនី បុរេប្រទាន បៀវត្ស លាភការ និងប្រាក់កម្រៃ (លេខ ១៥០៥៦)

ឥណទាន គណនី ប្រាក់បញ្ញើរបស់ក្រុង ស្រុក ខណ្ឌ នៅរតនាគារ (លេខ ១២០៣)។

**-កិច្ចបញ្ជិការបស់រតនាគារខេត្ត (គណនេយ្យថវិកាថ្នាក់ជាតិ)**

ឥណពន្ធ គណនី ប្រាក់បញ្ញើថវិការបស់ក្រុង ស្រុក ខណ្ឌ (លេខ ៤៤០៣)

ឥណទាន គណនី មូលប្បទានបត្រ ឬ បញ្ជាផ្ទេរបានបោះផ្សាយ (លេខ ១១០៧) ឬ

ឥណទាន គណនី ចរន្តនៅធនាគារ (លេខ ១១២១.../១១៣១...)។

**២.ពេលទូទាត់ជម្រះការផ្តល់បុរេប្រទានបៀវត្ស ប្រាក់កម្រៃ និងប្រាក់ឧបត្ថម្ភ**

ពេលទទួលបានអាណត្តិនិយ័តកម្ម ទូទាត់ជម្រះបុរេប្រទាន រតនាគារខេត្តកត់ត្រា÷

**-កិច្ចបញ្ជិការបស់រតនាគារខេត្ត (គណនេយ្យថវិកាក្រុង ស្រុក)**

ឥណពន្ធ គណនី ចំណាយថវិកា (លេខ ៦១../៦៤..)

ឥណទាន គណនី ប្រាក់បៀវត្ស និង លាភការត្រូវសង (លេខ ៤២០១) និង

ឥណពន្ធ គណនី ប្រាក់បៀវត្សនិងលាភការត្រូវសង (លេខ ៤២០១)

ឥណទាន គណនី បុរេប្រទាន បៀវត្ស លាភការ និងប្រាក់កម្រៃ (លេខ ១៥០៥៦)។

**V.ការទទួលឧបត្ថម្ភធន និងការទូទាត់ជម្រះប្រាក់ដែលបានផ្តល់មុនទៅគ្រឹះស្ថានមត្តេយ្យសិក្សា គ្រឹះស្ថានបឋមសិក្សា និងមជ្ឈមណ្ឌលសិក្សាសហគមន៍ ឬ មជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ**

**១.ការទទួលឧបត្ថម្ភធន**

ក្រោយពីទទួលបានប្រកាសឥណទានរបស់រតនាគារថ្នាក់កណ្តាល ស្តីពីការផ្ទេរឧបត្ថម្ភធនជូនរដ្ឋបាលក្រុង ស្រុក។

ការកត់ត្រា÷

**-កិច្ចបញ្ជិការបស់រតនាគារខេត្ត (គណនេយ្យថវិកាថ្នាក់ជាតិ)**

ឥណពន្ធ គណនី ទំនាក់ទំនងផ្ទេរប្រតិបត្តិការ (លេខ ៤៣០២)

ឥណទាន គណនី ប្រាក់បញ្ញើថវិការបស់ក្រុង ស្រុក ខណ្ឌ (លេខ ៤៤០៣)។

**-កិច្ចបញ្ជិការបស់រតនាគារខេត្ត (គណនេយ្យថវិកាក្រុង ស្រុក)**

ឥណពន្ធ គណនី ប្រាក់បញ្ញើរបស់ក្រុង ស្រុក ខណ្ឌ នៅរតនាគារ (លេខ ១២០៣)

ឥណទាន គណនី ឧបត្ថម្ភធនពីក្រសួង ស្ថាប័នសម្រាប់ធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌ(លេខ ៧៥០១៦)។

**២.ការទូទាត់ជម្រះបុរេប្រទានបន្ថែមសមតុល្យដែលរដ្ឋបាលក្រុង ស្រុក បានទទួល**

រតនាគារខេត្ត ត្រូវជម្រះដោយស្វ័យប្រវត្តិ នូវចំនួនទឹកប្រាក់បុរេប្រទានបន្ថែមសមតុល្យនៃគណនីប្រាក់បញ្ញើរបស់រដ្ឋបាលក្រុង ស្រុក ជាមួយឧបត្ថម្ភធន ដែលបានទទួល រួចជូនដំណឹងទៅរដ្ឋបាលក្រុង ស្រុក។

**-កិច្ចបញ្ជិការបស់រតនាគារខេត្ត (គណនេយ្យថវិកាថ្នាក់ជាតិ)**

ឥណពន្ធ គណនី ប្រាក់បញ្ញើថវិការបស់ក្រុង ស្រុក ខណ្ឌ (លេខ ៤៤០៣)

ឥណទាន គណនី បុរេប្រទានបន្ថែមសមតុល្យនៃគណនីប្រាក់បញ្ញើ (លេខ ១៥០៥៧)។

**-កិច្ចបញ្ជិការបស់រតនាគារខេត្ត (គណនេយ្យថវិកាក្រុង ស្រុក)**

ឥណពន្ធ គណនី បុរេប្រទាន ឬ រដ្ឋទេយ្យបុរេប្រទាន បានទទួល (លេខ ៤០០៥)

ឥណទាន គណនី ប្រាក់បញ្ញើរបស់ក្រុង ស្រុក ខណ្ឌ នៅរតនាគារ (លេខ ១២០៣)។

**VI.ការបង់សាច់ប្រាក់សល់ពីចំណាយរបស់គ្រឹះស្ថានមត្តេយ្យសិក្សា គ្រឹះស្ថានបឋមសិក្សា និងមជ្ឈមណ្ឌលសិក្សាសហគមន៍ ឬ មជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ ចូលគណនីចរន្តរបស់រតនាគារខេត្ត នៅធនាគារ**

**-កិច្ចបញ្ជិការបស់រតនាគារខេត្ត (គណនេយ្យថវិកាថ្នាក់ជាតិ)**

ឥណពន្ធ គណនី ចរន្តនៅធនាគារ (លេខ ១១២០.../១១៣០...)

ឥណទាន គណនី ប្រាក់បញ្ញើថវិការបស់ក្រុង ស្រុក ខណ្ឌ (លេខ ៤៤០៣)។

**-កិច្ចបញ្ជិការបស់រតនាគារខេត្ត (គណនេយ្យថវិកាក្រុង ស្រុក)**

ឥណពន្ធ គណនី ប្រាក់បញ្ញើថវិការបស់ក្រុង ស្រុក ខណ្ឌ នៅរតនាគារ (លេខ ១២០៣)

ឥណទាន គណនី ចំណាយមុនការធ្វើអាណត្តិកិច្ច (លេខ ១៥០៥៤)។

**VII.ការបង់សំណល់ចំណាយនៃការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ**

**១.**គណនេយ្យករថវិកាក្រុង ស្រុក ត្រូវគណនាទឹកប្រាក់លម្អៀងរវាងចំណូលថវិកាពីឧបត្ថម្ភធនពីក្រសួង ស្ថាប័នសម្រាប់ធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌ (លេខ ៧៥០១៦) និងទឹកប្រាក់ចំណាយសរុបរបស់គ្រឹះស្ថានមត្តេយ្យសិក្សា គ្រឹះស្ថានបឋមសិក្សា និងមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ (លេខ ៦...)។

**២.**ចំនួនទឹកប្រាក់លម្អៀង (ចំណុច ១) ត្រូវកត់ត្រានៅក្នុងគណនេយ្យរដ្ឋដោយបន្ថយពីចំនួនទឹកប្រាក់ចំណូលថវិកាឧបត្ថម្ភធនពីក្រសួង ស្ថាប័ន សម្រាប់ធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌ (លេខ ៧៥០១៦) និងបន្ថយពីគណនីប្រាក់បញ្ញើរបស់ក្រុង ស្រុក ខណ្ឌ នៅរតនាគារ (លេខ ១២០៣)។ ទន្ទឹមនឹងនោះ ក៏ត្រូវកត់ត្រានៅក្នុងគណនេយ្យថវិកាថ្នាក់ជាតិនូវ

គួលេខលម្អៀងនេះដោយផ្ទេរទៅរតនាគារថ្នាក់កណ្តាល ដើម្បីកត់ត្រាជាសំណែសចំណាយក្នុងឆ្នាំ។

**-កិច្ចបញ្ជិការបស់រតនាគារខេត្ត (គណនេយ្យថវិកាក្រុង ស្រុក)**

ឥណពន្ធ គណនី ឧបត្ថម្ភធនពីក្រសួង ស្ថាប័នសម្រាប់ធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌ (លេខ ៧៥០១៦)

ឥណទាន គណនី ប្រាក់បញ្ញើរបស់ក្រុង ស្រុក ខណ្ឌ នៅរតនាគារ (លេខ ១២០៣)។

**-កិច្ចបញ្ជិការបស់រតនាគារខេត្ត (គណនេយ្យថវិកាថ្នាក់ជាតិ)**

ឥណពន្ធ គណនី ប្រាក់បញ្ញើរបស់ក្រុង ស្រុក ខណ្ឌ (លេខ ៤៤០៣)

ឥណទាន គណនី ទំនាក់ទំនងផ្ទេរប្រតិបត្តិការ (លេខ ៤៣០២)។

**-កិច្ចបញ្ជិការបស់រតនាគារថ្នាក់កណ្តាល**

ឥណពន្ធ គណនី ទំនាក់ទំនងផ្ទេរប្រតិបត្តិការផ្សេង (លេខ ៤៣០២)

ឥណទាន គណនី ឧបត្ថម្ភធនដល់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌ (លេខ ៦៥០១៦)។

**បញ្ជាក់÷** រតនាគារខេត្តត្រូវផ្ញើទៅរតនាគារថ្នាក់កណ្តាលនូវ÷

-ប្រកាសឥណទាន

-លិខិតជូនដំណឹងឥណពន្ធ (គណនេយ្យថវិកាថ្នាក់ជាតិ)

-របាយការណ៍គណនាលម្អៀងនៃការអនុវត្តថវិការបស់គ្រឹះស្ថានមត្តេយ្យ គ្រឹះស្ថានបឋមសិក្សា និងមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ (ច្បាប់ថតចម្លង)។

**VIII.ការរៀបចំរបាយការណ៍**

១.គណនេយ្យករថវិកាក្រុង ស្រុក ត្រូវរៀបចំ÷

-តារាងតុល្យភាពគណនីសរុប ប្រចាំខែ ប្រចាំឆ្នាំ ផ្ញើជូនអគ្គនាយកដ្ឋានរតនាគារជាតិ

-របាយការណ៍គណនាលម្អៀងនៃការអនុវត្តថវិកាប្រចាំឆ្នាំរបស់គ្រឹះស្ថានមត្តេយ្យសិក្សា គ្រឹះស្ថានបឋមសិក្សា និងមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ ផ្ញើជូនអគ្គនាយកដ្ឋានរតនាគារជាតិ

-របាយការណ៍លទ្ធផលសរុបនៃការអនុវត្តថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលក្រុង ស្រុក ផ្ញើជូនអគ្គនាយកដ្ឋានរតនាគារជាតិ។

២.ការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង ស្រុក ត្រូវរៀបចំរបាយការណ៍ស្តីពីការអនុវត្តចំណូល ចំណាយថវិកាប្រចាំឆមាស និងប្រចាំឆ្នាំ រួចបញ្ជូនមកការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុនៃរដ្ឋបាលក្រុង ស្រុក ដើម្បីពិនិត្យ និងដាក់ជូនគណៈអភិបាលក្រុង ស្រុក ពិនិត្យសម្រេច។ រដ្ឋបាលក្រុង ស្រុក ត្រូវផ្ញើរបាយការណ៍អនុវត្តចំណូល ចំណាយថវិកាជូនមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីបូកសរុប រួចផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា)

៣.គ្រឹះស្ថានមត្តេយ្យសិក្សា គ្រឹះស្ថានបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធនៅរដ្ឋបាលក្រុង ស្រុក ទាំង ១៤ នៃខេត្តបាត់ដំបង ត្រូវរៀបចំរបាយការណ៍សមិទ្ធកម្ម (ប្រចាំឆមាស និងប្រចាំឆ្នាំ) ផ្អែកតាមសូចនាករសមិទ្ធកម្មដែលបានកំណត់ និងបញ្ជូនទៅការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ដើម្បីបូកសរុបក្នុងតារាងរបាយការណ៍សមិទ្ធកម្មរួម រួចបញ្ជូនមកការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុនៃរដ្ឋបាលក្រុង ស្រុក ដើម្បីពិនិត្យ និងដាក់ជូនគណៈអភិបាលក្រុង ស្រុក ពិនិត្យ

សម្រេច មុនដាក់ជូនក្រុមប្រឹក្សាក្រុង ស្រុក ពិនិត្យ អនុម័ត។ រដ្ឋបាលក្រុង ស្រុក ត្រូវផ្ញើរបាយការណ៍សមិទ្ធកម្ម ជូនរដ្ឋបាលខេត្ត មួយ(១) ច្បាប់ និងជូនមន្ទីរអប់រំ យុវជន និងកីឡា មួយ (១) ច្បាប់ ដើម្បីបូកសរុប និងផ្ញើជូនក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា)។

តារាងរបាយការណ៍មានជូនភ្ជាប់នៅឧបសម្ព័ន្ធនៃសារាចរនេះ។

## ផ្នែកទី ២÷ នីតិវិធីចលនាឥណទានថវិកា សម្រាប់ការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលក្រុង ស្រុកទាំង ១៤ នៃខេត្តបាត់ដំបង សម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ

ដើម្បីមានមូលដ្ឋានធ្វើចលនាឥណទានថវិកា សម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ រដ្ឋបាលក្រុង ស្រុក ទាំង ១៤ នៃខេត្តបាត់ដំបង ត្រូវអនុវត្តដូចខាងក្រោម÷

១.រដ្ឋបាលក្រុង ស្រុក មិនត្រូវបានអនុញ្ញាតឱ្យអនុវត្តចំណាយលើសពីទំហំឥណទានថវិកាដែលបានបែងចែកតាមសៀវភៅថវិកាប្រចាំឆ្នាំឡើយ លើកលែងតែមានការបន្ថែមឥណទានថវិកា, ការផ្ទេរឥណទានថវិកា ឬ ការធ្វើនិយ័តកម្មឥណទានថវិកា (ដែលត្រូវបានអនុញ្ញាតចាប់ពីត្រីមាសទី ២)។

២.រដ្ឋបាលក្រុង ស្រុក ត្រូវធ្វើសំណើសុំការអនុម័ត និងមានសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាក្រុង ស្រុក សម្រាប់ការធ្វើនិយ័តកម្មឥណទានថវិកា ពីអនុគណនីមួយ ទៅអនុគណនីមួយទៀត និង/ឬ ពីគណនីមួយ ទៅគណនីមួយទៀត ក្នុងជំពូកតែមួយ (ផ្ទៃក្នុងក្រុង ស្រុកតែមួយ) នៃចង្កោមសកម្មភាពតែមួយ ដោយមានការយល់ព្រមពីអភិបាលនៃគណៈអភិបាលខេត្ត។

៣.រដ្ឋបាលក្រុង ស្រុក ត្រូវធ្វើសំណើមកអគ្គនាយកដ្ឋានថវិកា និងចម្លងជូនអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់÷

-ការស្នើសុំបន្ថែមឥណទានថវិកា

-ការស្នើសុំនិយ័តកម្មឥណទានថវិកា (ផ្ទៃក្នុងក្រុង ស្រុកតែមួយ) ពីជំពូកមួយទៅជំពូកមួយទៀត, ពីចង្កោមសកម្មភាពមួយទៅចង្កោមសកម្មភាពមួយទៀត

-ការស្នើសុំធ្វើនិយ័តកម្មឥណទានថវិកាពាក់ព័ន្ធនឹងអនុគណនី ៦៤០២៣ (ប្រាក់បំណាច់ម៉ោងបន្ថែម) អនុគណនី ៦៤០២៦ (ប្រាក់បំណាច់តំបន់) និងអនុគណនី ៦៤០៤១ (បៀវត្សមូលដ្ឋាន បុគ្គលិកជាប់កិច្ចសន្យា)។

អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ អគ្គនាយកដ្ឋានថវិកា រតនាគារថ្នាក់កណ្តាល រតនាគារខេត្ត មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋបាលក្រុង ស្រុកទាំង១៤ នៃខេត្តបាត់ដំបង ត្រូវអនុវត្តសារាចរណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**ចម្លងជូន÷**

-ក្រសួងអប់រំ យុវជន និងកីឡា
-លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
-អគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ
-រដ្ឋបាលខេត្តបាត់ដំបង
-អគ្គនាយកដ្ឋានពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
"ដើម្បីជ្រាប"
-ឯកសារ-កាលប្បវត្តិ